ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៤

ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៧

សាលក្រមលេខ: ៩៤ -ខ-

ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០៨,៣០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

-ដើម្បីជំនុំជម្រះលើ: សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៤ ចុះថ្ងៃទី ០៤-០៤-២០១៧ អញ្ញតជន ត្រូវចោទពីបទ នឹងឈូសឆាយដីព្រៃ អនុផលធនធានធម្មជាតិដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុច UTM ២៧៩៦៣២-១២៣៦៨៦៩ ស្ថិតនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ១៧.០៣.២០១៧ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥៩ ចំណុច ៣ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ ៧៦ អ.យ/១៧ ចុះថ្ងៃទី ២១-០៦-២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

-បានឃើញ: ដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រេចឲ្យរឹបអូសវត្ថុតាង លេខ ១២០៦ ក.៣/១៧ ចុះថ្ងៃទី ២១-០៦-២០១៧ របស់ចៅក្រមសាលាដំបូងខេត្តកោះកុង ។

-បានឃើញ: ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ៧៩ ចុះថ្ងៃទី ២១-០៦-២០១៧ របស់លោកប្រធានសាលាដំបូងខេត្តកោះកុង ។

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ នៅចំណុច UTM ២៧៩៦៣២-១២៣៦៨៦៩ ស្ថិតនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានទូកកន្ទុយវែងមួយគ្រឿងបានធ្វើសកម្មភាពនឹងដឹកជញ្ជូនដល អនុផលធនធានធម្មជាតិ (បង្គោលស្នាច់) ដោយគ្មានការអនុញ្ញាត កើតឡើងដោយជនមិនស្គាល់មុខ។

នាពេលសវនាការ

-សាក្សីឈ្មោះ [redacted]ថាន បានឆ្លើយបញ្ជាក់នាពេលសវនាថា: កាលពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ៥,០០នាទីល្ងាចក្តី ក្រុមបង្ក្រាបបទល្មើសធនធានធម្មជាតិរបស់មន្ទីរបរិស្ថានខេត្តកោះកុង សហការជាមួយកម្លាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស... ភូមិភាគ៣ ក្រោមការឧបត្ថម្ភគាំពារអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចុះប្រតិបត្តិការ...



Scanned by CamScanner

បទល្មើសធនធានធម្មជាតិតាម ផ្លូវទឹក ត្រង់ចំណុច UTM ២៧៩៦៣២-១២៣៦៨៤៩ ស្ថិតនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានប្រទះឃើញ ទូកកន្ទុយវែងចំនួន ០១ គ្រឿង កំពុងដឹកជញ្ជូនផល អនុផលធនធាន ធម្មជាតិ (បង្គោលស្នាច់) ដោយគ្មានលិខិតអនុញ្ញាត ដែលប្រព្រឹត្តឡើងដោយជនមិនស្គាល់មុខ បានរត់គេចខ្លួនបាត់មុនពេលសមត្ថកិច្ចបានទៅដល់ ក្រោយពីបានពិនិត្យជាក់ស្តែងឃើញថា ការដឹកជញ្ជូនផលអនុផលព្រៃឈើ ធនធានធម្មជាតិ (បង្គោលស្នាច់) ខាងលើ មានការប្រាសចាកពីច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្រុមការងារបានធ្វើការចាប់យាត់ និងរឹបអូសប្រមូលវត្ថុតាងរួមមាន: បង្គោលស្នាច់ ចំនួន ១១២ដើម ទូកកន្ទុយវែងចំនួន ០១គ្រឿង និងម៉ាស៊ីនទូកចំនួន ០២គ្រឿង យកមករក្សាទុកជា បណ្តោះអាសន្ននៅស្នាក់ការកោះប៉ោ រួចហើយកសាងសំណុំរឿងទៅតាមនីតិវិធីច្បាប់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា: មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើ អញ្ញាតជន ពីបទ: ដឹកជញ្ជូនផល អនុផលធនធានធម្មជាតិដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុច UTM ២៧៩៦៣២-១២៣៦៨៤៩ ស្ថិតនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ១៧.០៣.២០១៧ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥៩ ចំណុច ៣ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។ តាងនាមតំណាងអយ្យការ សូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល និងស្នើសុំឲ្យតុលាការសម្រេចទៅតាមច្បាប់។

- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- ក្រោយពីបានពិនិត្យឯកសារផ្សេងៗជាភស្តុតាង

<u>ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ</u>

<u>យល់ឃើញថា:</u>

-កាលពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៧ នៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានអំពើល្មើស ដឹកជញ្ជូនផល អនុផលធនធានធម្មជាតិដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុច UTM ២៧៩៦៣២-១២៣៦៨៤៩ ស្ថិតនៅភូមិ០១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ១៧.០៣.២០១៧ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាម មាត្រា ៥៩ចំណុច ៣ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

-វត្ថុដែលចាប់យករួមមានបង្គោលស្នាច់ចំនួន ១១២ដើម ជាឈើរបស់រដ្ឋដែលជនល្មើសលួចកាប់យកដោយខុសច្បាប់ ដោយឡែកទូកកន្ទុយវែងចំនួន ០១គ្រឿង និងម៉ាស៊ីនទូកចំនួន០២ គឺជាឧបករណ៍ដែលជនជាប់ចោទប្រើជាមធ្យោបាយ សម្រាប់ប្រព្រឹត្តបទល្មើស គប្បីតុលាការរឹបអូសជាសម្បត្តិរដ្ឋ នូវរាល់វត្ថុដែលចាប់ទាំងអស់តាមច្បាប់ ។

## <u>ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង</u>

## <u>វិនិច្ឆ័យសេចក្តី</u>

១/- <u>វត្ថុដែលចាប់យករួមមាន:</u> បង្គោលស្នាច់ចំនួន ១១២ (មួយរយដប់ពីរ)ដើម ទូកកន្ទុយវែងចំនួន ០១ (មួយ) គ្រឿង, និងម៉ាស៊ីនទូកចំនួន ០២ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

២/- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាធារណៈ នៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ហត្ថលេខា និងត្រា [redacted]

ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កោះកុង, ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៧
ក្រឡាបញ្ជីសាលាការ

ចៅក្រមជំនុំជម្រះ

[redacted]

[redacted]



Scanned by CamScanner